**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៦២៤ [illegible]/ភម

ថ្ងៃ អង្គារ ៦កើត ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២១

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ជម្រាបជូន

## លោកជំទាវ/ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត

**កម្មវត្ថុ:** ការត្រៀមរៀបចំសម្រាប់ឆ្លើយតបនៅពេលមានគ្រោះអាសន្ន គ្រោះមហន្តរាយកើតឡើងជាយថាហេតុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប**លោកជំទាវ/ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត** ជ្រាបថា ការប្រែប្រួលអាកាសធាតុធ្វើឱ្យមានការផ្លាស់ប្តូរនូវរដូវកាល របបទឹកភ្លៀង និងបង្កឱ្យកើតមាននូវគ្រោះធម្មជាតិ ដូចជារលកកម្តៅ ផ្គររន្ទះ ខ្យល់កន្ត្រាក់ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ដល់ ហេដ្ឋារចនាសម្ព័ន្ធ ទ្រព្យសម្បត្តិ សុខភាព និងស្លាប់បាត់បង់អាយុជីវិតប្រជាជន។ ដូចនេះ ដើម្បីកាត់បន្ថយឱ្យបានជា អតិបរមា នូវផលប៉ះពាល់ដល់សុខភាព និងមូលដ្ឋានសុខាភិបាល ពីគ្រោះធម្មជាតិទាំងនោះ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត មេត្តាយកចិត្តទុកដាក់ត្រៀមលក្ខណៈជាមុន សម្រាប់ឆ្លើយតបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ក្នុងការសង្គ្រោះ ថែទាំសុខភាពប្រជាជនរងគ្រោះដូចជា៖

- រៀបចំក្រុមការងារសង្គ្រោះ និងព្យាបាលប្រជាជនរងគ្រោះ ជាពិសេសសេវាសម្រាលកូនដោយសុវត្ថិភាព
- ត្រៀមឱសថ សំភារៈបរិក្ខារ មធ្យោបាយដែលត្រូវការចាំបាច់សម្រាប់ការចុះអន្តរាគមន៍
- តាមដានការប្រែប្រួលធម្មជាតិ និងធ្វើការផ្សព្វផ្សាយជូនមន្ត្រីក្រោមឱវាទនិងប្រជាជន ដើម្បីមានវិធានការចូលរួមសហការទប់ស្កាត់បានទាន់ពេលវេលា
- ផ្តល់របាយការណ៍បន្ទាន់ករណីជំងឺ របួស-ស្លាប់ អំពើហិង្សាលើស្ត្រីនិងកុមារ ការខូចខាតឧបករណ៍សម្ភារៈមូលដ្ឋានសុខាភិបាលដោយសារគ្រោះធម្មជាតិមក នាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាលឱ្យបានរួសរាន់ដើម្បីក្រសួងមានលទ្ធភាពចូលរួមឆ្លើយតបបានទាន់ពេលវេលា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **លោកជំទាវ/ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត** នឹងខិតខំប្រឹងប្រែងយកចិត្តទុកដាក់អនុវត្តការងារត្រៀមលក្ខណៈសម្រាប់ឆ្លើយតបនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម**លោកជំទាវ/ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត** ទទួលនូវការរាប់អានពីខ្ញុំ។

**ម៉ម ប៊ុនហេង**

__ចម្លងជូន៖__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី-ខេត្ត
- អង្គភាពពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងសុខាភិបាល អគារលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩